ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០០២........អ.ស.ហ.សជ្រន.

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តគម្រោងស្តីពីការលើកកម្ពស់អនុលោមភាពគណនេយ្យ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានអនុម័ត និងដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥**" នាសម័យប្រជុំលើកទី២០ អាណត្តិទី១ កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤។ ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រខាងលើ គឺ "**ប្រព័ន្ធគណនេយ្យនិងសវនកម្មដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន**" សសរស្តម្ភទី៤ បានកំណត់អំពីសកម្មភាពជាយុទ្ធសាស្ត្រ "**ការលើកកម្ពស់កម្រិតអនុលោមភាព**" និងបានបញ្ជាក់ក្នុងចំណុចទី៤ "**ការពិចារណា កែសម្រួលនិងស្នើដាក់ចេញវិធានគ្រប់គ្រងជាធរមាន និងបំពេញបន្ថែមដើម្បីលើកកម្ពស់កម្រិតអនុលោមភាព**"។ ដូច្នេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រនេះ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សម្រេចដាក់ចេញសេចក្តីណែនាំដូចខាងក្រោម៖

### ក).ការដាក់ឱ្យអនុវត្ត

ត្រូវបានដាក់ឱ្យអនុវត្តគម្រោងស្តីពី "**ការលើកកម្ពស់អនុលោមភាពគណនេយ្យ**" ដែលរៀបចំឡើងដោយនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។ គម្រោងនេះ សំដៅដល់កម្មវិធីបណ្តុះបណ្តាលដែលមានប្រធានបទដូចខាងក្រោម៖

១. ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវៈ
២. គោលការណ៍ និងនីតិវិធីគណនេយ្យ ដែលផ្អែកតាមក្របខ័ណ្ឌកាត់បន្ថយការរាយការណ៍ហិរញ្ញវត្ថុកម្ពុជា ឬស្តង់ដាការរាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
៣. មាតិកាគណនីនៃប្លង់គណនេយ្យសហគ្រាស ឬមាតិកាគណនីនៃប្លង់គណនេយ្យអង្គភាពមិនស្វែងរកប្រាក់ចំណេញ
៤. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល
៥. ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** តាមប្រព័ន្ធ E-filing។

### ខ).ស្ថាប័នអនុវត្ត

១. **ន.គ.ស.** ជាស្ថាប័នអភិវឌ្ឍ និងគ្រប់គ្រងគម្រោង។ **ន.គ.ស.** ត្រូវរៀបចំឧបករណ៍គាំទ្រការបណ្តុះបណ្តាលទាំងជារូបវន្តនិងឌីជីថល សៀវភៅសិក្សា និងសម្ភារៈសម្រាប់ការបណ្តុះបណ្តាល។ កម្មវិធីបណ្តុះបណ្តាលក្រោមគម្រោងនេះអាចអនុវត្តដោយ **ន.គ.ស.** ផ្ទាល់ និង/ឬ **ន.គ.ស.** អាចផ្តល់សិទ្ធិក្នុងការអនុវត្តការបណ្តុះបណ្តាលនេះដល់គ្រឹះស្ថានបណ្តុះបណ្តាលដោយធ្វើឡើងតាមរយៈការចុះអនុស្សារណៈនៃការយោគយល់គ្នា។ លក្ខខណ្ឌទាក់ទងនឹងការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាល ការលើកលែងមុខវិជ្ជាសិក្សានិង/ឬប្រឡង បែបបទ នីតិវិធី និងកម្រៃនៃការបណ្តុះបណ្តាល ព្រមទាំងការចេញវិញ្ញាបនបត្រនិង/ឬលក្ខខណ្ឌបន្ថែមនានា ត្រូវកំណត់ដោយ **ន.គ.ស.**។
២. គ្រឹះស្ថានបណ្តុះបណ្តាលដែលត្រូវបានទទួលស្គាល់ពី **ន.គ.ស.** ក្នុងការផ្តល់ការបណ្តុះបណ្តាលផ្អែកតាមកម្មវិធីបណ្តុះបណ្តាល និងបទប្បញ្ញត្តិនានា នឹងត្រូវកំណត់ក្រោមគម្រោងនេះ។

#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia

ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

**គ).បុគ្គលតម្រូវឱ្យចូលរួមការបណ្តុះបណ្តាល**

១. រាល់អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យករបម្រើការងារក្នុង(១)ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម (២)សហគ្រាសទូទៅដែលមិនអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និង (៣)អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ត្រូវឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលក្រោមគម្រោងខាងលើ និង/ឬទទួលបានវិញ្ញាបនបត្របញ្ជាក់ការប្រឡងជាប់កម្មវិធីបណ្តុះបណ្តាលនេះ។

២. ប្រធានក្រុមហ៊ុន/សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវតម្រូវឱ្យរាល់អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យករក្រោមការគ្រប់គ្រងរបស់ខ្លួនទទួលការបណ្តុះបណ្តាលក្នុងកម្មវិធីបណ្តុះបណ្តាលក្រោមគម្រោងខាងលើ ឬមានវិញ្ញាបនបត្របញ្ជាក់ការប្រឡងជាប់កម្មវិធីបណ្តុះបណ្តាលនេះ។

៣. អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យករដែលបានទទួលការបណ្តុះបណ្តាលក្នុងកម្មវិធីបណ្តុះបណ្តាលខាងលើ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលបន្តដែលកំណត់ដោយ **ន.គ.ស.**។

**ឃ).ការលើកទឹកចិត្តពីការចូលរួមវគ្គបណ្តុះបណ្តាល**

ក្រុមហ៊ុន/សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចាត់អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យកររបស់ខ្លួនឱ្យទទួលការបណ្តុះបណ្តាលក្នុងកម្មវិធីបណ្តុះបណ្តាលខាងលើ អាចត្រូវបានលើកទឹកចិត្តដូចខាងក្រោម៖

ក. ការមិនដាក់ក្រុមហ៊ុន/សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញឱ្យទទួលរងការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មក្នុងរយៈពេលណាមួយដោយ **ន.គ.ស.**។

ខ. អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យករដែលចូលរួមការបណ្តុះបណ្តាលក្នុងកម្មវិធីបណ្តុះបណ្តាលខាងលើត្រូវបានលើកទឹកចិត្តឱ្យចូលជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជាអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ និយ័តករគណនេយ្យនិងសវនកម្ម ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងគ្រប់អ្នកពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃ អង្គារ ៧រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.
- គ្រប់សមាសភាពនៃក្រុមប្រឹក្សា អ.ស.ហ.
  "ដើម្បីជូនជ្រាប"
- និយ័តករគណនេយ្យនិងសវនកម្ម "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ